# ការវិភាគនៅលើមូលហេតុដែលបណ្ដាលឲ្យចំនួន

# អនីតិជនជាប់ឃុំនៅកម្ពុជាមានការកើនឡើង



unicef CAMBODIA | for every child

# ការប្រែប្រួលនៃចំនួនអនីតិជនជាប់ឃុំ ២០១០-២០១៧




ប្រភពព័ត៌មាន៖ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានពន្ធនាគារ
មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាអំពីពន្ធនាគារ




ប្រភពព័ត៌មាន៖ ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានពន្ធនាគា ឆ្នាំ២០១៧
ទិន្នន័យខែវិច្ឆិកា២០១៦ ៖ សាលាឧទ្ធរណ៍

# ការប្រែប្រួលនៃចំនួនអនីតិជនជាប់ឃុំ ២០១០-២០១៧

រូបភាពទី២៖ ចំនួនអនីតិជនជាប់ឃុំដែលមានអាយុក្រោម១៨ឆ្នាំ




❖ កត្តានាំឲ្យថយចុះ (៥៦.៥ ភាគរយចន្លោះឆ្នាំ២០១០និង ២០១៤)៖

- ការកសាងសមត្ថភាពចៅក្រម ព្រះរាជអាជ្ញា មេធាវី អំពីយន្តការយុត្តិធម៌កុមារមេត្រី។
- កិច្ចប្រជុំសម្របសម្រួលជាទៀងទាត់រវាង នគរបាល តុលាការនិងពន្ធនាគារ ព្រមទាំង កិច្ចសហការស៊ីជំរៅរវាងតុលាការនិងពន្ធនាគារ។
- កម្មវិធីបង្វែរដែលគាំទ្រដោយអង្គការជាតិនិង អន្តរជាតិ
  - ➢ បណ្តាញតស៊ូមតិយុវជនសហគមន៍៖ ពត៍មានការបង្វែរតាមរយៈការបង្ការនិងការ ប្រាស្រ័យទាក់ទង(អង្គការជំនួយផ្នែកច្បាប់ កម្ពុជា)
  - ➢ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅ សៀមរាបនិងការតាមដានកុមារដោយមន្ត្រី សង្គមកិច្ចនៅពេលធ្វើសមាហរណកម្មទៅ សហគមន៍វិញ(អង្គការកល្យាណមិត្ត)។
- ការចុះត្រួតពិនិត្យជាទៀងទាត់ (LICADHO, OHCHR, ICRC)។
- កាគ្រប់គ្រងករណីប្រកបដោយប្រសិទ្ធិភាព មេធាវី ការសម្របសម្រួលឲ្យមានការដោះលែងដោយមាន លក្ខខណ្ឌ(អរគុណដល់UNICEFដែលបានផ្តល់ ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដល់ក្រសួង ស អយ)។

# វិបត្តិនៃចំនួនអនីតិជនជាប់ឃុំ ២០១០-២០១៧




❖ កត្តានាំឲ្យមានការកើនឡើងពីឆ្នាំ២០១៥:

- អនីតិជនដែលត្រូវបានចាប់ខ្លួនក្នុងយុទ្ធនាការបង្ក្រាបគ្រឿងញៀន
- ការថយចុះនូវជនធានា
- ការបញ្ឈប់កម្មវិធីបណ្តុះបណ្តាល
- ការថយចុះនៃគម្រោងជំនួយផ្នែកច្បាប់
- ខ្វះយន្តការអនុវត្តជម្រើសផ្សេងក្រៅពីការឃុំខ្លួន
- ខ្វះការយល់ដឹងនិងជំនាញក្នុងចំណោមអ្នកធ្វើការខាងយុត្តិធម៌អនីតិជន
- ខ្វះការផ្សព្វផ្សាយនៅតាមសហគមន៍

# ការចូលរួមយោបលក្នុងការកាត់បន្ថយចំនួនអនីតិជនជាប់ឃុំ

*ការបង្ការ*

- ផ្តល់ជូនសមាជិកសហគមន៍(ដែលរួមមានបណ្តាញសហគមន៍ ប្រធានភូមិ នគរបាលឃុំ គ្រូបង្រៀន/នាយកសាលា កុមារ ក្មេងជំទង់ និងគ្រួសារ)នូវចំនេះដឹងខាងសិទ្ធិកុមារនិងការយល់ដឹងពីគុណសម្បត្តិនៃការបង្វែរនិងគុណវិបត្តិនៃការឃុំខ្លួន។
- ផ្សព្វផ្សាយពត៌មាននិងធនធានដើម្បីលើកទឹកចិត្តឲ្យមានការអនុវត្តល្អៗ(ការសិក្សារ យុទ្ធនាការផ្សព្វផ្សាយ)។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជននិងបទប្បញ្ញត្តិទាក់ទងនឹងសិទ្ធិកុមារជាផ្នែកមួយនៃកម្មវិធីសិក្សារដល់មន្ត្រីតុលាការ នគរបាល និង ឆ្មាំពន្ធនាគារ។
- សហការជាមួយក្រសួងអប់រំយុវជននិងកីឡា ដើម្បីបញ្ចូលសិទ្ធិកុមារនិងប្រធានបទទាក់ទងនឹងយុត្តិធម៌អនីតិជនទៅក្នុងកម្មវិធីសិក្សាសម្រាប់កុមារ។
- កែលម្អការតស៊ូមតិពីអ្នកនយោបាយជាន់ខ្ពស់។
- តស៊ូមតិឲ្យមានការបង្ការគ្រឿងញៀន និង ការស្តារនិតិសម្បទាសម្រាប់អនីតិជនព្រមទាំងការបង្វែរអនីតិជនប្រព្រឹត្តបទល្មើសចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទ ណ្ឌ។
- ពង្រឹងការអនុវត្តយន្តការចុះសំបុត្រកំណើតឲ្យមានប្រសិទ្ធិភាព។

# ការអនុវត្តមាន់

- ផ្តល់ជូននគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រម មេធាវី និងមន្ត្រីសង្គមកិច្ចនូវចំនេះដឹងពាក់ព័ន្ធសិទ្ធិកុមារ៖
  - ការបណ្តុះបណ្តាលស្តីពីច្បាប់យុត្តិធម៌អនីតិជន ការបង្វែរ និតិវិធីកុមារមេត្រី ព្រមទាំងបទប្បញ្ញត្តិបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ(ដែលរួមបញ្ចូលទាំងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងវិធានក្រុងប៉េកាំង)
  - ចុះត្រួតពិនិត្យឲ្យបានទៀងទាត់បន្ទាប់ពីការបណ្តុះបណ្តាល។

- កែលម្អការប្រាស្រ័យទាក់ទងនិងកិច្ចសហការនៅគ្រប់ជាន់ថ្នាក់ និងលើកទឹកចិត្តនាយនគរបាលឲ្យផ្តល់ជាកំលាំងចិត្តដល់មន្ត្រីនគរបាលឲ្យអនុវត្តយន្តការបង្វែរក្រៅប្រព័ន្ធមានដូចជាការព្រមានជាដើម។

- ពង្រឹងការអនុវត្តដំណោះស្រាយនៅថ្នាក់សហគមន៍ចំពោះបទល្មើសលហុតាមរយៈសន្ធានកម្មដែលមានការចូលរួមពីព្រះសង្ឃជាដើម។

- ពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ ដូចជាសារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការអនុវត្តទោសការងារសហគមន៍។ល។ និងបង្កើតគោលការណ៍ណែនាំ និតិវិធីប្រតិបត្តិការស្តង់ដាដើម្បីណែនាំដល់ការអនុវត្តបទប្បញ្ញត្តិច្បាប់ដែលចូលជាធរមាន។

- ពង្រឹងការអនុវត្តវិធានការបង្វែរ ដោយរួមបញ្ចូលការបណ្តុះបណ្តាលវិជ្ជាជីវៈ/បំណិនជីវិត ប្រឹក្សាយោបល់ ការគាំទ្រផ្នែកសង្គមកិច្ច។ ពង្រឹងការអនុវត្តវិធានការពិសេសសម្រាប់ជនល្មើសគ្រឿងញៀនដែលរួមមានដូចជាការបន្សាប ការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។

- ផ្តល់ជូនចៅក្រមនូវរបាយការប៉ាន់ប្រមាណសុខមាលភាពនិងស្ថានភាពសង្គមរបស់កុមារ ដែលរបាយការនេះមានភាពចាំបាច់ដល់ការសម្រេចចិត្តលើការកាត់សេចក្តី។

- បណ្តុះបណ្តាលមន្ត្រីសង្គមកិច្ចពីរបៀបធ្វើការប៉ាន់ប្រមាណលើស្ថានភាពអនីតិជនប្រព្រឹត្តបទល្មើសដើម្បីឲ្យពួកគេអាចសេសេររបាយការប៉ាន់ប្រមាណសុខមាលភាពនិងស្ថានភាពសង្គមរបស់កុមារ និងត្រួពិនិត្យការងាររបស់ពួកគេ។

- ចុះអធិការកិច្ចដោយទៀងទាត់និងត្រួតពិនិត្យតាមពន្ធនាគារដើម្បីប៉ាន់ប្រមាណស្ថានភាពកុមារ។

- ពង្រឹងជំនួយផ្នែកយុត្តិធម៌និងអ្នកតំណាងផ្នែកច្បាប់។

- សម្របសម្រួលឲ្យមានការដោះលែងដោយមានលក្ខខណ្ឌដោយផ្អែកលើរបាយការប៉ាន់ប្រមាណសុខមាលភាពនិងស្ថានភាពសង្គមរបស់កុមារ និងការប៉ាន់ប្រមាណលើអនីតិជន។

## សមាហរណកម្ម

- បង្វែរអនីតិជនដែលជាប់ទោសទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានលក្ខណៈកុមារមេត្រីដើម្បីត្រៀមពួកគេសម្រាប់សមាហរណកម្មទៅកាន់សហគមន៍។ សម្របសម្រួលសមាហរណកម្មតាមរយៈការគាំទ្រនិងតាមដានដោយមន្ត្រីសង្គមកិច្ច។

- គាំទ្រនិងតាមដានសមាហរណកម្មអនីតិជននៅក្នុងសហគមន៍របស់ពួកគេបន្ទាប់ពីការដោះលែង(យ៉ាងហោចណាស់៦ខែ)។

- ទាំនក់ទំនងជាមួយផ្នែកឯកជននិងភ្នាក់ងារជាតិការងារដើម្បីលើកទិកចិត្តមានការជ្រើសរើសអតីតអ្នកប្រព្រឹត្តបទល្មើសដែលបានកែខ្លួន។

## ផ្នែកហិរញ្ញវត្ថុ

- ជួយរាជរដ្ឋាភិបាលធ្វើការសិក្សារស្តីពីថវិការចំណាយរបស់រាជរដ្ឋាភិបាលលើផ្នែកយុត្តិធម៌អនីតិជន។